| **គោលការណ៍ និងនីតិវិធី** | |
|---|---|
| **ឋានៈ៖**<br>ទំនាស់ផលប្រយោជន៍ | |
| **ម្ចាស់បណ្ណសន្យារ៉ាប់រងតាមផ្នែក៖**<br>អនុលោមភាព | **លេខបណ្ណសន្យារ៉ាប់រង៖**<br>CMP23 |
| **ផ្នែកដែលរងផលប៉ះពាល់៖** | |
| ☐ រដ្ឋបាល<br>☐ បណ្ដឹងទាមទារសំណង<br>☐ អនុលោមភាព<br>☐ ផ្នែកសេវាបម្រើអតិថិជន<br>☐ កិច្ចការខាងក្រៅ<br>☐ មណ្ឌល<br>☐ ហិរញ្ញវត្ថុ | ☐ ធនធានមនុស្ស<br>☐ បច្ចេកវិទ្យាព័ត៌មាន<br>☐ ទីផ្សារ<br>☐ ការគ្រប់គ្រងវេជ្ជសាស្ត្រ<br>☐ បណ្ដាញអ្នកផ្ដល់សេវា<br>☐ ការគ្រប់គ្រងគម្រោង<br>☒ ទាំងអស់ |

| | |
|---|---|
| **កាលបរិច្ឆេទមានប្រសិទ្ធភាព៖**<br>10/01/2016 | **កាលបរិច្ឆេទត្រួតពិនិត្យ/កែប្រែ៖**<br>11/18, 12/19, 04/21, 08/21 |
| **កាលបរិច្ឆេទអនុម័តការត្រួតពិនិត្យគោលការណ៍របស់គណៈកម្មការ៖**<br>PRC៖ 02/19 07/20, 08/21 | **កាលបរិច្ឆេទដកចេញ៖** |
| **ប្រភេទផលិតផល៖**<br>Medi-Cal | **ជំនួស៖**<br>លេខ និងចំណងជើងបណ្ណសន្យារ៉ាប់រង៖ |

## I. គោលបំណង

ដើម្បីដោះស្រាយច្បាប់សហព័ន្ធ បទប្បញ្ញត្តិ ស្តង់ដាទទួលស្គាល់ និងលក្ខខណ្ឌតម្រូវសម្រាប់ស្នងការ, និយោជិតដែលបានជ្រើសតាំង (DE), សមាជិកគណៈកម្មការខាង

ក្រៅ និងនិយោជិត (និយោជិត) របស់គម្រោងថែទាំសុខភាព Health Plan of San Joaquin/Mountain Valley Health Plan ("HPSJ/MVHP") ឱ្យជៀសវាងទំនាស់ផលប្រយោជន៍ (COI)។ HPSJ/MVHP នឹងធានាថានីតិវិធីត្រូវបានដាក់ចេញសម្រាប់ការបញ្ចេញព័ត៌មាន និងការគ្រប់គ្រងស្ថានការណ៍ដែលអាចនាំឱ្យមានទំនាស់ផលប្រយោជន៍ រួមទាំងការធ្វើទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់បច្ចុប្បន្ន និងអនាគត ដើម្បីការពារសុចរិតភាពរបស់ HPSJ/MVHP។

## II. គោលការណ៍

គោលការណ៍នេះគ្រប់គ្រងលក្ខខណ្ឌតម្រូវនៃកិច្ចសន្យារវាង DHCS និង HPSJ/MVHP ដែលទាក់ទងនឹងបទប្បញ្ញត្តិទំនាស់ផលប្រយោជន៍នៃចំណងជើងទី 22 CCR ផ្នែក 53874 និង 53600 និងកិច្ចសន្យា DHCS, ឧបសម្ព័ន្ធ A, ឯកសារភ្ជាប់ 1, មាត្រា 3.A។

A. HPSJ/MVHP មិនត្រូវប្រើមន្ត្រីរដ្ឋ បុគ្គលិក ឬប្រពន្ធ/ស្វាមី ឬកូនអនីតិជនរបស់គាត់ក្នុងសេវាកម្មស៊ីវិលរដ្ឋ ឬមន្ត្រីរដ្ឋដែលត្រូវបានតែងតាំងផ្សេងទៀតទេ លើកលែងតែការងារ សកម្មភាព ឬអាជីវកម្មត្រូវបានតម្រូវជាលក្ខខណ្ឌនៃការងាររដ្ឋប្រចាំរបស់មន្ត្រី ឬបុគ្គលិកនោះ។

B. HPSJ/MVHP មិនត្រូវធ្វើកិច្ចសន្យាជាមួយអ្នកម៉ៅការបន្តណាម្នាក់ទេ ប្រសិនបើបុគ្គលណាម្នាក់ក្នុងចំណោមបុគ្គលដូចខាងក្រោមដែលភ្ជាប់ជាមួយគម្រោងមានផលចំណេញផ្នែកហិរញ្ញវត្ថុជាមួយអ្នកម៉ៅការបន្តនោះ៖

1. បុគ្គលទាំងឡាយក៏មានផលចំណេញផ្នែកហិរញ្ញវត្ថុក្នុងគម្រោង។
2. អ្នកត្រួតពិនិត្យសុខភាព ឬនិយោជិតទាំងឡាយរបស់គម្រោង

3. សមាជិកគ្រួសារជិតស្និទ្ធណាម្នាក់របស់បុគ្គលដែលត្រូវបានកំណត់ក្នុងចំណងជើង 22 CCR §53600 (d)។

C. តម្រូវឱ្យអ្នកត្រួតពិនិត្យសុខភាព ឬនិយោជិតរបស់ HPSJ/MVHP បញ្ចេញស្ថានការណ៍ដែលអាចបង្ហាញទំនាស់ផលប្រយោជន៍ភ្លាមៗ ឬការលេចឡើងនៃទំនាស់ផលប្រយោជន៍ដោយដាក់សេចក្តីថ្លែងការណ៍អំពីការបញ្ចេញទំនាស់ផលប្រយោជន៍ HPSJ/MVHP។ ប្រធានផ្នែកអនុលោមភាព (CCO) ឬតំណាងដែលគាត់បានជ្រើសតាំងនឹងស៊ើបអង្កេតឧប្បត្តិហេតុ និងស្ថានការណ៍ដែលអាចបង្កឱ្យមានទំនាស់ផលប្រយោជន៍ភ្លាមៗ និងដើម្បីដោះស្រាយឧប្បត្តិហេតុ/ស្ថានការណ៍ដូចនេះ ដើម្បីធានាថាការសម្រេចចិត្តត្រូវបានធ្វើឡើងជាផលប្រយោជន៍ល្អបំផុតរបស់ HPSJ/MVHP, និយោជិត និងសមាជិករបស់ខ្លួន។

D. សមាជិកគណៈកម្មការ និងគណៈកម្មការរងរបស់ HPSJ/MVHP ត្រូវតែទទួលស្គាល់ការយល់ដឹងរបស់ពួកគាត់អំពីការអនុវត្តទំនាស់ផលប្រយោជន៍របស់ HPSJ/MVHP ដោយពិនិត្យមើលគោលការណ៍នេះ និងដាក់បញ្ជូនរបាយការណ៍ស្តីពីការទទួលស្គាល់នៅពេលក្លាយជាសមាជិកគណៈកម្មការ និងជារៀងរាល់ឆ្នាំបន្ទាប់ពីនោះ។

E. បុគ្គលិកដែលបានជ្រើសតាំងរបស់ HPSJ/MVHP ត្រូវតែដាក់ស្នើសេចក្តីថ្លែងការណ៍ផលប្រយោជន៍សេដ្ឋកិច្ច ទម្រង់បែបបទ 700 (ទម្រង់បែបបទ 700) នៅពេលជួលបុគ្គលិក និងជារៀងរាល់ឆ្នាំបន្ទាប់ពីនោះតាមកាលបរិច្ឆេទកំណត់ដែលប្រកាសដោយគណៈកម្មាធិការការអនុវត្តនយោបាយដោយយុត្តិធម៌នៃរដ្ឋកាលីហ្វ័រញ៉ា (FPPC)។

F. សមាជិកនិយោជិតផ្សេងទៀតដែលមិនមែនជា DE ទាំងអស់ត្រូវតែទទួលស្គាល់ការយល់ដឹងរបស់ពួកគេអំពីការអនុវត្តលើទំនាស់ផលប្រយោជន៍របស់ HPSJ/MVHP ដោយពិនិត្យមើលគោលការណ៍នេះ (CMP 23) និងដាក់ស្នើរបាយការណ៍អំពីការទទួលស្គាល់នៅពេលជួលនិយោជិត និងជារៀងរាល់ឆ្នាំបន្ទាប់ពីនោះ។ របាយការណ៍អំពីការទទួលស្គាល់ត្រូវដាក់បញ្ជូនទៅផ្នែកអនុលោមភាព និងរក្សាទុកក្នុងឃ្លាំងកណ្ដាលសម្រាប់គោលបំណងរក្សាទុកកំណត់ត្រា។

G. និយោជិត HPSJ/MVHP ត្រូវបានតម្រូវឱ្យប្រកាន់ខ្ជាប់នឹងនីតិវិធីដែលបានរៀបរាប់ក្នុងគោលការណ៍នេះ។

## III. នីតិវិធី

A. និយមន័យបុគ្គលិកដែលបានជ្រើសតាំង

1. បុគ្គលិកដែលបានជ្រើសតាំងដែលត្រូវបានតម្រូវឱ្យបំពេញសេចក្តីថ្លែងការណ៍ផលប្រយោជន៍សេដ្ឋកិច្ច ទម្រង់បែបបទ 700 (ទម្រង់បែបបទ 700) ត្រូវបានរាយបញ្ជីក្នុងប្រភេទបញ្ចេញដូចខាងក្រោម៖
   a. អ្នកត្រួតពិនិត្យសុខភាពទាំងអស់
   b. ប្រធានទាំងអស់
   c. នាយកទាំងអស់
   d. អ្នកគ្រប់គ្រង ឬនិយោជិតដែលជ្រើសរើសដែលអាចស្នើសុំអ្នកផ្គត់ផ្គង់ និងចូលរួម ឬមានឥទ្ធិពលក្នុងការធ្វើការសម្រេចចិត្តទិញបាន

e. អ្នកប្រឹក្សាយោបល់ ឬអ្នកចុះកិច្ចសន្យាមួយចំនួនដែលមានសមត្ថភាពដូចដែលរាយបញ្ជីខាងលើជាលក្ខណៈបណ្ដោះអាសន្ន នៅពេលពួកគាត់ធ្វើ ចូលរួមធ្វើ ឬធ្វើសកម្មភាពតំណាងឱ្យបុគ្គលិកសម្រាប់ការសម្រេចចិត្តហិរញ្ញវត្ថុ កិច្ចសន្យា និង/ឬថវិកា។

DE ត្រូវតែបញ្ចេញការវិនិយោគ ផលប្រយោជន៍ក្នុងអចលនទ្រព្យ តួនាទីអាជីវកម្ម និងចំណូលពេញលេញ (រួមទាំងប្រាក់កម្ចី អំណោយ និងប្រាក់សេវាធ្វើដំណើរ) ដោយបំពេញទម្រង់បែបបទ 700 តាមកាលបរិច្ឆេទកំណត់ដែលប្រកាសដោយគណៈកម្មាធិការផ្នែកអនុវត្តនយោបាយដោយយុត្តិធម៌នៃរដ្ឋកាលីហ្វ័រញ៉ា (FPPC)។

B. ការទិញ និងការធ្វើកិច្ចសន្យា

1. ការជ្រើសរើសផលិតផល និងសេវាកម្មត្រូវតែផ្អែកលើលក្ខណៈវិនិច្ឆ័យព្យាបាលត្រឹមត្រូវ (ឧទាហរណ៍ គុណភាព សុវត្ថិភាព និងប្រសិទ្ធភាព) និង/ឬ លក្ខខណ្ឌអាជីវកម្ម (ឧទាហរណ៍ លទ្ធភាពផ្តល់ជូនអត្ថប្រយោជន៍ថ្លៃចំណាយ ការបង្កើតថ្មី បទប្បញ្ញត្តិ និងតម្លៃ) និងធ្វើឡើងដើម្បីផលប្រយោជន៍សុខុមាលភាពអ្នកជំងឺ និងដើម្បីផលប្រយោជន៍ល្អបំផុតរបស់ HPSJ/MVHP និងធនធានហិរញ្ញវត្ថុរបស់ខ្លួន។
2. ម្ចាស់អាជីវកម្មដែលទទួលខុសត្រូវ ឬក្រុមការងារគម្រោងត្រូវតែប្រកាន់ខ្ជាប់នឹងគោលការណ៍ CMP26 និង FIN14 នៅពេលជ្រើសរើសផលិតផល ឬសេវាកម្មពីអ្នកផ្គត់ផ្គង់ខាងក្រៅ។
3. បុគ្គលិកដែលបានជ្រើសតាំងដោយ HPSJ/MVHP ដែលមានសិទ្ធិក្នុងការដឹកនាំ ឬមានឥទ្ធិពលលើ

ការជ្រើសរើស ឬការទិញផលិតផល និងសេវាកម្ម ត្រូវតែមានសេចក្ដីថ្លែងការណ៍បង្ហាញទំនាស់ផលប្រយោជន៍បច្ចុប្បន្ន ដែលបានបញ្ជាក់ ទម្រង់បែបបទ 700 និងសេចក្ដីថ្លែងការណ៍បង្ហាញអំពីអំណោយ (ប្រសិនបើមាន) នៅក្នុងឯកសារ។

4. សមាជិកនិយោជិតក្នុងការផ្ដល់សេវាវេជ្ជសាស្ត្រ/ឱសថដល់សមាជិកមានការសម្រេចចិត្តក្នុងការទាក់ទង និង/ឬស្នើសុំព័ត៌មានពីក្រុមហ៊ុនវេជ្ជសាស្ត្រ និង/ឬឱសថ ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុនវេជ្ជសាស្ត្រ ឬឱសថមិនអាចស្នើសុំឱ្យបញ្ចូលផលិតផលរបស់ពួកគាត់ទៅក្នុងបញ្ជីឱសថដោយគ្មានការអញ្ជើញពីអង្គភាពគ្រប់គ្រងវេជ្ជសាស្ត្រ HPSJ/MVHP ឡើយ។
5. ប្រសិនបើទំនាស់ ឬទំនាស់ដែលអាចកើតមានកើតឡើង និយោជិត HPSJ/MVHP ត្រូវតែបញ្ជូនទំនាស់នោះទៅអ្នកត្រួតពិនិត្យរបស់ពួក

គាត់ និងផ្នែកអនុលោមភាព ដើម្បីធានាថាទំនាស់ត្រូវបានដោះស្រាយយ៉ាងសមរម្យ។ ការដោះស្រាយសមរម្យអាចរួមបញ្ចូលការដកខ្លួនចេញពីការចូលរួមក្នុងការសម្រេចចិត្តទាក់ទងនឹងការជ្រើសរើសអ្នកផ្គត់ផ្គង់ និង/ឬសេវាកម្ម ការលើកលែងពីការអនុម័ត។

C. ការទទួលយកអំណោយពីអ្នកផ្គត់ផ្គង់ និងអ្នកលក់

1. និយោជិត HPSJ/MVHP ដែលមានឥទ្ធិពលលើការជ្រើសរើសអ្នកផ្គត់ផ្គង់សម្រាប់ផលិតផល និងសេវាកម្ម មិនអាចទទួលយកអ្វីដែលមានតម្លៃដែលផ្តល់ដោយអ្នកផ្គត់ផ្គង់បានទេ។

2. និយោជិត HPSJ/MVHP អាចចូលរួមក្នុងការចាប់ឆ្នោតដែលឧបត្ថម្ភដោយអ្នកផ្គត់ផ្គង់តាមរយៈការប្រើប្រាស់កាតអាជីវកម្មរបស់ពួកគាត់ ឬផ្តល់ព័ត៌មានទំនាក់ទំនងអាជីវកម្ម HPSJ/MVHP នៅពេលបង្ហាញផលិតផលសាក

ល្បែង សន្និសីទអ្នកផ្គត់ផ្គង់ ឬកម្មវិធីផ្សេងទៀត ដូចជាសាលតាំងពិព័រណ៍ ប្រសិនបើអ្នកចូលរួមទាំងអស់មានមានសិទ្ធិទទួលបានវត្ថុនោះប៉ុណ្ណោះ។

3. ការទទួលយកអំណោយពីអតិថិជនបច្ចុប្បន្ន ឬនាពេលអនាគត អ្នកផ្គត់ផ្គង់ ឬគូប្រជែង ដែលជាម្ចាស់ផលប្រយោជន៍ហិរញ្ញវត្ថុ ឬបម្រើការក្នុងតួនាទីអាជីវកម្មជាមួយសហគ្រាសខាងក្រៅដែលធ្វើ ឬចង់ធ្វើអាជីវកម្មជាមួយ ឬជាគូប្រជែងរបស់ HPSJ/MVHP ត្រូវតែមានករណីដូចខាងក្រោម៖

   a. ភ្លាមៗនៅពេលទទួលអំណោយដែលមិនទាន់ប្រើដែលមានតម្លៃលើសពីហាសិបដុល្លារ ($50) អំណោយនោះត្រូវតែដាក់បញ្ជូនទៅផ្នែកអនុលោមភាពដែលនឹងផ្ញើត្រឡប់អំណោយនោះទៅអ្នកផ្តល់វិញ ឬបញ្ជូនអំណោយនោះទៅដៃគូសហគមន៍

HPSJ/MVHP ដែលជាអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលលើកលែងពីការបង់ពន្ធ។

b. ការទទួលអំណោយដែលមានតម្លៃតិចតួចហាសិបដុល្លារ ($50) ឬតិចជាងនេះ គួរត្រូវបានប្រាប់ឱ្យដឹងក្នុងចំណោមបុគ្គលិក (ឧទាហរណ៍ ប្រអប់សូកូឡា)។

c. អាហារថ្ងៃត្រង់ពេលមានសន្និសីទ អាហារពេលល្ងាច ឬរង្វាន់ចាប់ឆ្នោតត្រូវបានអនុញ្ញាត ប្រសិនបើអ្នកចូលរួមទាំងអស់មានសិទ្ធិទទួលបានវត្ថុនោះ។

D. ការផ្គត់ផ្គង់អាហារដោយអ្នកផ្គត់ផ្គង់

1. មុនពេលចុះកិច្ចសន្យា អាហារដែលផ្តល់ដោយអ្នកផ្គត់ផ្គង់**<u>មិន</u>** ត្រូវបានអនុញ្ញាតទេ។

2. បន្ទាប់ពីចុះកិច្ចសន្យារួច អាហារដែលផ្តល់ដោយអ្នកផ្គត់ផ្គង់**ត្រូវបានអនុញ្ញាត**សម្រាប់ការប្រជុំ

រៀបចំគម្រោងឬការប្រជុំពិនិត្យលទ្ធផល ដរាបណាការប្រជុំទាំងនេះត្រូវបានធ្វើឡើងក្នុងអំឡុងម៉ោងធ្វើការប្រចាំការិយាល័យ។

3. បន្ទាប់ពីការចូលរួម ឬការអនុវត្តមួយចប់ និយោជិត HPSJ/MVHP **<u>មិនអាច</u>** ចូលរួមការទទួលទានអាហារអបអរសាទរដែលឧបត្ថម្ភដោយអ្នកផ្គត់ផ្គង់ HPSJ/MVHP បានទេ (ឧទាហរណ៍ សកម្មភាពមួយដែលនិយោជិត HPSJ/MVHP និងអ្នកផ្គត់ផ្គង់បានចូលរួមយ៉ាងសកម្មនិងយ៉ាងជិតស្និទ្ធ ហើយអ្នកផ្គត់ផ្គង់ចង់រៀបចំពិធីទទួលទានអាហារជំជេង)។

E. ការផ្តល់ការកម្សាន្តដោយអ្នកផ្គត់ផ្គង់

និយោជិត HPSJ/MVHP **<u>មិន</u>** អាចទទួលយកសំបុត្រឥតគិតថ្លៃពីអ្នកផ្គត់ផ្គង់ ដើម្បីចូលរួមកីឡា ឬព្រឹត្តិការណ៍កម្សាន្តប្រភេទផ្សេងទៀតបាន

ទេ។ លក្ខខណ្ឌតម្រូវនេះអនុវត្តមិនថាចំពោះអ្នកផ្តត់ផ្គង់មានវត្តមាន ឬមិនមានវត្តមានឡើយ។

F. ការគាំទ្រអ្នកផ្គត់ផ្គង់ចំពោះសកម្មភាពអប់រំ និងវិជ្ជាជីវៈផ្សេងទៀត

1. HPSJ/MVHP ទទួលយកជំនួយមូលនិធិសម្រាប់ការគាំទ្រទូទៅនៃការអប់រំពីអ្នកផ្គត់ផ្គង់ ប្រសិនបើជំនួយមូលនិធិដែលមិនមានការកំណត់ត្រូវបានផ្តល់ដោយមានការអនុញ្ញាតពីគណៈកម្មាធិការសុខភាព និង/ឬនាយកប្រតិបត្តិ ហើយមិនត្រូវបានកំណត់សម្រាប់ការប្រើប្រាស់ដោយបុគ្គលជាក់លាក់ទេ។

2. ជំនួយមូលនិធិអប់រំមិនអាចត្រូវបានផ្តល់ជូនកំណត់លក្ខខណ្ឌ ឬពាក់ព័ន្ធតាមរបៀបណាមួយនឹងទំនាក់ទំនងអាជីវកម្មដែលមានស្រាប់ ឬនាពេលអនាគតជាមួយអ្នកផ្គត់ផ្គង់ ឬផលិតផល និងសេវាកម្មរបស់ពួកគាត់ រួមទាំងការសម្រេច

ចិត្តស្ដីពីស្ថានភាពជានារ៉ាប់រង ឬបញ្ញើផលិតផលថ្នាំទេ។

3. និយោជិត HPSJ/MVHP អាចចូលរួមសិក្ខាសាលាអប់រំដែលឧបត្ថម្ភដោយអ្នកផ្ដត់ផ្ដង់ (ឧ. សិក្ខាសាលាតាមអ៊ីនធឺណិត បទពិសោធ បច្ចុប្បន្នភាពឧស្សាហកម្ម ដរាបណាអ្នកផ្ដត់ផ្ដង់មិនលើកលែងថ្លៃចុះឈ្មោះ)។ នៅពេលដែលសិក្ខាសាលាអប់រំទាំងនោះបើកឱ្យសាធារណជនចូលរួម និងមានការបញ្ចេញព័ត៌មាន ទាក់ទងការចូលរួមរបស់សមាជិកនិយោជិត HPSJ/MVHP ត្រូវទៅកាន់អ្នកគ្រប់គ្រងរបស់និយោជិតមុនពេលចូលរួម។

4. ការចូលរួមរបស់និយោជិត HPSJ/MVHP នៅក្នុងក្រុមប្រឹក្សាដែលឧបត្ថម្ភដោយអ្នកផ្ដត់ផ្ដង់ត្រូវបានហាមឃាត់ បើមិនមានការអនុញ្ញាតពីគណៈកម្មាធិការ ឬប្រធានផ្នែកអនុលោមភាពទេ។ ការសម្រេចចិត្តទាក់ទងនឹងការចូលរួមរបស់

និយោជិតក្នុងការប្រជុំបែបនេះត្រូវផ្អែកលើការកំណត់របស់សមាជិកក្រុមប្រតិបត្តិថា ការចូលរួមក្នុងការប្រជុំបែបនេះគឺដើម្បីផលប្រយោជន៍ល្អបំផុតរបស់ HPSJ/MVHP។

5. និយោជិត HPSJ/MVHP **<u>មិនអាច</u>** តំណាងឱ្យ HPSJ/MVHP នៅពេលជួបអ្នកផ្គត់ផ្គង់ ឬក្រុមពិភាក្សាប្រភេទផ្សេងទៀតដែលរៀបចំដោយអ្នកផ្គត់ផ្គង់ ឬតំណាងរបស់ពួកគាត់បានទេ បើមិនមានការអនុញ្ញាតពីសមាជិកក្រុមប្រតិបត្តិទេ។ ការចូលរួមក្នុងក្រុមពិភាក្សាដែលពិភាក្សាអំពីផលិតផល ឬសេវាកម្មដែលប្រើប្រាស់ដោយ HPSJ/MVHP គឺសមរម្យ នៅពេលដែលក្រុមត្រូវបានរៀបចំ ឬអនុញ្ញាតដោយ HPSJ/MVHP។

6. និយោជិត HPSJ/MVHP **<u>មិនអាច</u>** ទទួលយកផលិតផលឥតគិតថ្លៃពីអ្នកផ្គត់ផ្គង់សម្រាប់ការចែកចាយនៅព្រឹត្តិការណ៍សហគមន៍បានទេ។

7. HPSJ/MVHP អាចចូលទៅក្នុងទំនាក់ទំនងផ្លូវការជាមួយអ្នកផ្គត់ផ្គង់ ដើម្បីចែកចាយសេវាកម្មបញ្ចុះតម្លៃដល់សមាជិក និងបុគ្គលិកតាមកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរដែលបានអនុញ្ញាត។ ការបញ្ចុះតម្លៃពីអ្នកផ្គត់ផ្គង់ដែលមិនស្ថិតក្រោមកិច្ចព្រមព្រៀងផ្លូវការ HPSJ/MVHP ត្រូវបានហាមឃាត់។

G. ការធ្វើដំណើរដែលឧបត្ថម្ភដោយអ្នកផ្គត់ផ្គង់

និយោជិត HPSJ/MVHP **ត្រូវបានលើកទឹកចិត្ត**ពីការអង្វរ ឬទទួលយកការសងប្រាក់វិញពីអ្នកផ្គត់ផ្គង់សម្រាប់ការចូល ការធ្វើដំណើរតាមអាកាស និងការស្នាក់នៅ ថ្លៃធ្វើដំណើរពី និងទៅព្រលានយន្តហោះ ការធ្វើដំណើរបញ្ចុះតម្លៃពិសេស ឬការចំណាយដែលពាក់ព័ន្ធ ដើម្បីចូលរួមការបង្ហាញផលិតផល សន្និសីទ ឬកម្មវិធីអប់រំ។ ប្រសិនបើទទួលយក និយោជិតមានទំនួលខុសត្រូវ ដើម្បី

ធានាថា ការចំណាយដែលពាក់ព័ន្ធណាមួយត្រូវបានរាយការណ៍/បញ្ចេញនៅលើទម្រង់បែបបទសេចក្តីថ្លែងការណ៍ផលប្រយោជន៍សេដ្ឋកិច្ច 700 (គណៈកម្មាធិការការអនុវត្តនយោបាយដោយយុត្តិធម៌នៃរដ្ឋកាលីហ្វ័រញ៉ា)។

a. ទោះជាយ៉ាងណាក៏ដោយ ករណីលើកលែងដូចខាងក្រោមអាចអនុវត្តបាន៖

   i. ការធ្វើដំណើរ និងការចំណាយដែលពាក់ព័ន្ធជាមួយការបណ្តុះបណ្តាលសម្រាប់ផលិតផលដែលទិញថ្មី ឬធ្វើឱ្យប្រសើរឡើងត្រូវបានអនុញ្ញាត។

   ការរៀបចំដំណើរបណ្តុះបណ្តាលផលិតផលត្រូវតែធ្វើឡើងដោយប្រើគោលការណ៍ការធ្វើដំណើររបស់ HPSJ/MVHP ហើយដាក់បញ្ជូន ដើម្បីទទួលបានការសងប្រាក់ពីអ្នកផ្គត់ផ្គង់។

ii. ការធ្វើដំណើរ និងការចំណាយដែលពាក់ព័ន្ធដែលបង់ដោយសមាគមវិជ្ជាជីវៈអាចទទួលយកបាន នៅពេលសមាជិកនិយោជិតជាអ្នកបង្ហាញក្នុងការប្រជុំ ឬសមាជិកស្ម័គ្រចិត្តនៃការគ្រប់គ្រងសមាគម (ឧទាហរណ៍ ក្រុមប្រឹក្សា ឬគណៈកម្មការ) ឬអ្នកចូលរួមក្នុងការពិភាក្សា ឬវគ្គរៀបចំគម្រោង។ ការធ្វើដំណើរ និងការចំណាយដែលពាក់ព័ន្ធត្រូវតែបញ្ជូនដល់អ្នកគ្រប់គ្រងរបស់សមាជិកនិយោជិតមុនពេលធ្វើដំណើរ។

H. ថ្លៃសេវា និងប្រាក់សំណងអ្នកនិយាយដែលផ្តល់ដោយអ្នកផ្គត់ផ្គង់

និយោជិត**<u>មិនអាច</u>** ទទួលយក និងរក្សាទុកថ្លៃសេវា និងប្រាក់សំណងអ្នកនិយាយ ឬអ្វីផ្សេងទៀតដែលមានតម្លៃពីអ្នកផ្គត់ផ្គង់សម្រាប់ការបង្រៀន ឬការ

ធ្វើបទបង្ហាញបានទេ រួមទាំងការទូទាត់សម្រាប់ពេលវេលា ការចំណាយធ្វើដំណើរ អាហារ ការកម្សាន្ត សកម្មភាពកម្សាន្ត ឬសកម្មភាពសង្គម។

I. ទំនាក់ទំនងរបស់និយោជិតជាមួយអ្នកផ្គត់ផ្គង់ HPSJ/MVHP

1. និយោជិត HPSJ/MVHP **មិនអាច**បម្រើការជាសមាជិកក្រុមប្រឹក្សាគ្រប់គ្រងរបស់អ្នកផ្គត់ផ្គង់ HPSJ/MVHP បានទេ។
2. និយោជិត HPSJ/MVHP **មិនអាច** ក្លាយជាអ្នកផ្គត់ផ្គង់ដល់ HPSJ/MVHP ខណៈពេលដែលកំពុងធ្វើការនៅ HPSJ/MVHP បានទេ។
3. និយោជិត HPSJ/MVHP **មិនអាច** ត្រូវបានជួលដោយអ្នកផ្គត់ផ្គង់ដែលធ្វើការឱ្យ HPSJ/MVHP បានទេ។

4. និយោជិត HPSJ/MVHP **<u>មិនអាច</u>** ក្លាយជាអ្នកចុះកិច្ចសន្យាដល់អ្នកផ្គត់ផ្គង់សម្រាប់កិច្ចសន្យា ឬការងារដែលអតិថិជនជា HPSJ/MVHP បានទេ។
5. សមាជិកនិយោជិត HPSJ/MVHP ដែលចូលទៅក្នុងការណាត់ជួប/ទំនាក់ទំនង ការរៀបការ ការចូលរួម ដៃគូក្នុងគេហដ្ឋាន ឬទំនាក់ទំនងអាជីវកម្មជាមួយអ្នកផ្គត់ផ្គង់ត្រូវតែជូនដំណឹងដល់អ្នកគ្រប់គ្រងរបស់ពួកគាត់ ភ្លាមៗនៅពេលដែលពួកគាត់ដឹងអំពីការផ្លាស់ប្តូរស្ថានភាពនៃទំនាក់ទំនងរបស់ពួកគាត់។

J. បន្ថែមពីលើការបំពេញទម្រង់បែបបទ 700 ប្រចាំឆ្នាំ និងការបញ្ចេញ HPSJ/MVHP តាមតម្រូវការ និយោជិតមានជម្រើសផ្សេងទៀត ដើម្បីបញ្ចេញស្ថានការណ៍ដែលទំនាស់ផលប្រយោជន៍អាចមាន។ ជម្រើសមួយទៀតសម្រាប់ការរាយការណ៍អាចប្រើបានសម្រាប់សមាជិកនិយោជិតដែលដឹងអំពីទំនាស់ផល

ប្រយោជន៍ដែលអាចកើតមានពាក់ព័ន្ធនឹងនិយោជិតម្នាក់ទៀត។

1. ការពិគ្រោះជាមួយនាយក និង/ឬអ្នកគ្រប់គ្រង

   និយោជិត HPSJ/MVHP ត្រូវតែរាយការណ៍អំពីទំនាស់ផលប្រយោជន៍ដែលអាចកើតមានឡើង និងត្រូវបានលើកទឹកចិត្តឱ្យពិគ្រោះជាមួយនាយក និង/ឬអ្នកគ្រប់គ្រងរបស់ពួកគាត់ ដើម្បីបញ្ជាក់អំពីស្ថានភាពភាពប្រឈមផលប្រយោជន៍ដែលអាចកើតមានឡើង។

2. ការបញ្ចេញជាលាយលក្ខណ៍អក្សរអំពីទំនាស់ផលប្រយោជន៍ដែលអាចកើតមានឡើង

   a. និយោជិត HPSJ/MVHP និង/ឬ DE ត្រូវតែដាក់ពាក្យបញ្ចេញជាលាយលក្ខណ៍អក្សរតាមរយៈក្រមប្រតិបត្តិ និងសីលធម៌ HPSJ/MVHP (ក្រម HPSJ/MVHP) នៅពេលដែលមាន

កាលៈទេសៈកើតឡើងក្នុងអំឡុងពេលនៃឆ្នាំ ដោយឡែកពីការបញ្ចេញព័ត៌មានប្រចាំឆ្នាំ។

b. បុគ្គលដែលមានតួនាទីជាអ្នកដឹកនាំ និងអ្នកគ្រប់គ្រង និងនិយោជិត HPSJ/MVHP ផ្សេងទៀតដែលចង់ ឬត្រូវបានស្នើសុំឱ្យចូលរួមក្នុងក្រុមប្រឹក្សាសហគមន៍ ត្រូវតែបញ្ចេញផលប្រយោជន៍របស់ពួកគាត់ និងស្វែងរកការអនុញ្ញាតពីអ្នកប្រធានផ្នែកអនុលោមភាព។

3. ការរាយការណ៍ក្តីកង្វល់អំពីទំនាស់ផលប្រយោជន៍ដែលអាចកើតមានឡើង

សមាជិកនិយោជិត HPSJ/MVHP ដែលដឹងអំពីស្ថានភាពទំនាស់ផលប្រយោជន៍ដែលអាចកើតមានឡើងនៅក្នុងស្ថាប័ន ត្រូវតែរាយការណ៍ស្របតាមក្រុម HPSJ/MVHP និងគោលការណ៍ទំនាស់ផលប្រយោជន៍។

K. ការវាយតម្លៃទំនាស់ផលប្រយោជន៍

1. ស្ថានភាពទំនាស់ផលប្រយោជន៍នីមួយៗមានភាពខុសគ្នា និងគួរតែត្រូវបានវាយតម្លៃលើមូលដ្ឋានគុណតម្លៃ។ មិនមែនគ្រប់ស្ថានភាពទាំងអស់ទាមទារឱ្យមានការអនុវត្តទេ។ នេះជាការសំខាន់ក្នុងការកំណត់ថាតើផលប្រយោជន៍ផ្ទាល់ខ្លួនមានសក្តានុពលធ្វើឱ្យប៉ះពាល់ដល់តួនាទី និងការទទួលខុសត្រូវវិជ្ជាជីវៈ និង/ឬការវិនិច្ឆ័យដែរឬទេ។ ការពិគ្រោះជាមួយប្រធានផ្នែកអនុលោមភាពគួរតែត្រូវបានស្នើសុំ។

2. លក្ខណៈវិនិច្ឆ័យដែលប្រើដើម្បីកំណត់ថាតើការសម្រេចចិត្តមានភាពចាំបាច់ គួរពិចារណាលើចំណុចខាងក្រោម៖

   a. ដើម្បីប្រកាន់ខ្ជាប់ និងការពារតម្លៃស្នូល និងបេសកកម្មរបស់ HPSJ/MVHP

b. ដើម្បីការពារផលប្រយោជន៍អាជីវកម្មរបស់ HPSJ/MVHP
c. ដើម្បីការពារសុចរិតភាពរបស់បុគ្គលដែលធ្វើការជំនួសស្ថាប័ន
d. តើទំនាស់ផលប្រយោជន៍នេះនឹងត្រូវបានយល់ថាមិនសមរម្យដោយនិយោជិត HPSJ/MVHP, សមាជិក HPSJ/MVHP ឬសាធារណជនទេ?
e. តើបុគ្គលណាម្នាក់កំពុងទទួលបានផលប្រយោជន៍ខាងហិរញ្ញវត្ថុ ឬសង្គមពីការអនុវត្តនេះដែរឬទេ?
f. តើនេះជាទម្លាប់អនុវត្តដែល HPSJ/MVHP ចង់ប្រកាន់ខ្ជាប់នាពេលអនាគតដែរឬទេ?

L. ការកំណត់ចំណាត់ការសមស្រប

ទំនាស់ផលប្រយោជន៍ណាមួយដែលសមនឹង និង/ឬត្រូវការចំណាត់ការគួរពិចារណាលើចំណុចខាងក្រោម។ ចំណាត់ការត្រូវបានដាក់ចេញ ដើម្បីការពារផលប្រយោជន៍ល្អបំផុតរបស់ស្ថាប័ន។ អាស្រ័យលើស្ថានការណ៍ ចំណុចខាងក្រោមគួរត្រូវបានពិចារណា៖

a. តើបុគ្គលនោះបានទទួល និងទទួលស្គាល់ការយល់ដឹងអំពីក្រមប្រតិបត្តិ និងគោលការណ៍ទំនាស់ផលប្រយោជន៍នៅពេលជួលបុគ្គលិក និងប្រចាំឆ្នាំបន្ទាប់ពីនោះដែរឬទេ?
b. តើបុគ្គលនោះបានបញ្ជាក់អំពីទំនាស់ផលប្រយោជន៍ដោយបំពេញទម្រង់បែបបទ 700 និង ឬការបញ្ចេញព័ត៌មាន HPSJ/MVHP ដែរឬទេ?

c. តើបុគ្គលនោះបានបញ្ចេញព័ត៌មានដោយខ្លួនឯងនៅពេលវេលាសមស្រប ឬបន្ទាប់ពីពេលដែលទំនាស់ផលប្រយោជន៍ត្រូវបានរកឃើញដែរឬទេ?

d. តើកម្រិតធ្ងន់ធ្ងរនៃហានិភ័យដែលទំនាស់ផលប្រយោជន៍បង្កឡើងចំពោះជំហរវិជ្ជាជីវៈ និង ឬភាពអព្យាក្រឹតរបស់បុគ្គលមានកម្រិតណា?

e. តើកម្រិតធ្ងន់ធ្ងរនៃហានិភ័យដែលទំនាស់ផលប្រយោជន៍បង្កឡើងចំពោះតម្លៃស្នូល និងកេរ្តិ៍ឈ្មោះរបស់ HPSJ/MVHP មានកម្រិតណា?

M. សកម្មភាពដែលមិនត្រូវបានអនុញ្ញាត

1. ការទទួលយកអំណោយលើសពី $50 ឬប្រាក់កម្ចីពីអតិថិជនបច្ចុប្បន្ន ឬនាពេលអនាគត អ្នកផ្គត់

ផ្គត់ ឬគូប្រជែង ដែលជាម្ចាស់ផលប្រយោជន៍ហិរញ្ញវត្ថុ ឬមានតួនាទីអាជីវកម្មជាមួយសហគ្រាសខាងក្រៅដែលធ្វើ ឬចង់ធ្វើអាជីវកម្មជាមួយ ឬជាគូប្រជែងរបស់ HPSJ/MVHP។

2. សមាជិកគ្រួសាររបស់និយោជិត HPSJ/MVHP ទទួលផលប្រយោជន៍ផ្ទាល់ខ្លួនមិនសមរម្យ ដោយសារតែការចូលរួមរបស់និយោជិតជាមួយ HPSJ/MVHP ដោយមិនមានដំណើរការស្នើសុំសំណើ (RFP) ធម្មតា។

3. អ្នកផ្គត់ផ្គង់ HPSJ/MVHP ផ្តល់ការកម្សាន្តលក្ខណៈអាជីវកម្ម។ ចំណាំ៖

   ករណីនេះមិនអនុវត្តចំពោះខ្លឹមសារផ្សព្វផ្សាយដែលមិនបានស្នើសុំនៃលក្ខណៈផ្សាយពាណិជ្ជកម្មទូទៅដូចជា ប៊ិកដែលមានឈ្មោះក្រុមហ៊ុនបោះពុម្ពលើ បន្ទះកំណត់ហេតុ។ល។ ដរាបណាអ្វីដែលផ្តល់ជូននោះត្រូវបានទទួលយកដោយមិនមានការ

យល់ដឹងច្បាស់លាស់ ឬបញ្ជាក់ថាអ្នកទទួលមានកាតព្វកិច្ចក្នុងវិធីណាមួយ។

4. អំឡុងពេលចរចាជាមួយអ្នកផ្តល់សេវាដែលចុះកិច្ចសន្យាសក្តានុពល HPSJ/MVHP មិនអាចទទួលយកការកម្សាន្តលក្ខណៈអាជីវកម្ម (រាប់បញ្ចូលទាំងការឧបត្ថម្ភអាហារថ្ងៃត្រង់ និងអាហារពេលល្ងាច) និង/ឬអំណោយរបស់អតិថិជន។

N. សេចក្តីថ្លែងការណ៍អំពីការបញ្ចេញព័ត៌មាន

1. តម្រូវឱ្យអ្នកត្រួតពិនិត្យ, DE និងសមាជិកគណៈកម្មការដាក់ស្នើទម្រង់បែបបទ 700 នៅពេលជួលបុគ្គលិក ឬពេលចាប់ផ្តើមជាសមាជិក និងប្រចាំឆ្នាំបន្ទាប់ពីនោះ។ ពួកគាត់ក៏ត្រូវតម្រូវឱ្យដាក់បញ្ជូនលិខិតបញ្ចេញព័ត៌មាន HPSJ/MVHP និងសេចក្តីថ្លែងការណ៍អំពីការបញ្ចេញព័ត៌មានអំណោយ HPSJ/MVHP ទៅតាមតម្រូវការផងដែល។

2. និយោជិត HPSJ/MVHP ដែលមិនត្រូវបាន កំណត់ជានិយោជិតដែលបានជ្រើសតាំងត្រូវតែ បំពេញទម្រង់បែបបទបញ្ចេញព័ត៌មាន HPSJ/MVHP និងលិខិតបញ្ចេញព័ត៌មាន អំណោយនៅពេលដឹងពីទំនាស់ផលប្រយោជន៍ ហើយដកខ្លួនចេញពីការចូលរួមក្នុងការទិញ ឬ ការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុណាមួយ។
3. ផ្នែកអនុលោមភាពនឹងរក្សាទុកកំណត់ត្រានៃ ទម្រង់បែបបទ 700 និងទម្រង់បែបបទបញ្ចេញ ព័ត៌មាន HPSJ/MVHP ដែលបានបំពេញទាំង អស់។

O. ផលវិបាកនៃការមិនអនុលោមតាមច្បាប់

ការខកខានក្នុងការអនុលោមតាមលក្ខខណ្ឌ តម្រូវនៃគោលការណ៍នេះ នឹងធ្វើឱ្យសមាជិក និយោជិតទទួលរងចំណាត់វិធានការកែតម្រូវ និង/ឬវិន័យ និងឈានដល់ការបញ្ឈប់ការងារ។

## IV. ឯកសារភ្ជាប់

A. សេចក្តីថ្លែងការណ៍អំពីការបញ្ចេញទំនាស់ផលប្រយោជន៍ HPSJ/MVHP

B. សេចក្តីថ្លែងការណ៍ FPPC អំពីផលប្រយោជន៍សេដ្ឋកិច្ចទម្រង់បែបបទ 700

C. តំណនៃសទ្ទានុក្រមពាក្យវាក្យសព្ទ

## V. ឯកសារយោង

A. ចំណងជើង 22 CCR §18930-18961

B. ចំណងជើង 22 CCR ផ្នែក 53874 និង 53600

C. កិច្ចសន្យា HPSJ/MVHP និង DHCS (ឧបសម្ព័ន្ធ A, ឯកសារភ្ជាប់ 1. មាត្រា 3.A។)

D. 42 U.S.C. §1320a-លក្ខន្តិកៈប្រឆាំងនឹងការទទួលប្រាក់សគុណ 7b

E. 42 CFR §438.608, §438.610 និង §455

F. ក្រមរដ្ឋាភិបាលរដ្ឋកាលីហ្វ័រញ៉ា §81000 to §91014

G. គណៈកម្មាធិការការអនុវត្តនយោបាយដោយយុត្តិធម៌នៃរដ្ឋកាលីហ្វ័រញ៉ា (Gov. Code, §§ 1090 et seq.)., [ច្បាប់កំណែទម្រង់នយោបាយ (ច្បាប់)]()

H. ក្រមសុខុមាលភាព និងក្រមស្ថាប័នផ្នែក 14087.31(k), 14087.35(p)(1), 14087.36(v)(1), 14087.38(h) និង 14087.969 (22 CCR §53874).

I. ឯកសារណែនាំអំពីធនធានច្បាប់ DHHS ប្រឆាំងនឹងការក្លែងបន្លំលើការថែទាំសុខភាព ខែកញ្ញា ឆ្នាំ 2015

J. គោលការណ៍ណែនាំអំពីការបញ្ជូនបន្តករណីទាក់ទងនឹងការក្លែងបន្លំ ការខ្ជះខ្ជាយ និងការបំពានចំពោះការប្រើប្រាស់ដោយគម្រោងថែទាំដែលស្ថិតក្រោមការគ្រប់គ្រង ខែឧសភា ឆ្នាំ 2012

K. កម្មវិធីអនុលោមភាព HPSJ/MVHP

L. ក្រមប្រតិបត្តិ និងសីលធម៌ HPSJ/MVHP

M. សេចក្តីថ្លែងការណ៍អំពីការបញ្ចេញទំនាស់ផលប្រយោជន៍ HPSJ/MVHP

N. សេចក្តីថ្លែងការណ៍អំពីការបញ្ចេញអំណោយ HPSJ/MVHP

O. កិច្ចព្រមព្រៀងយោគយល់នៃគម្រោងថែទាំសុខភាព Health Plan of San Joaquin និង SEIU Local 1021 ផ្នែក 14

P. ច្បាប់សន្តិសុខសង្គម §1128

## VI. ការអនុម័តរបស់ទីភ្នាក់ងារនិយតកម្ម

មិនអាចអនុវត្តបាន

## VII. ប្រវត្តិនៃការកែប្រែ

| ស្ថានភាព | កាលបរិច្ឆេទកែប្រែ | សេចក្ដីសង្ខេបអំពីកំណែ |
|---|---|---|
| បានកែប្រែ | 11/28/18 | បានធ្វើបច្ចុប្បន្នភាព P&P ដើម្បីដាក់ក្នុងទម្រង់គំរូ P&P ថ្មី និងដើម្បីជាការបញ្ជាក់ឱ្យច្បាស់។ |
| បានកែប្រែ | 11/27/19 | ធ្វើបច្ចុប្បន្នភាពអ្នកដែលត្រូវតម្រូវឱ្យបំពេញទម្រង់បែបបទ 700 និងឯកសារពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ប្រចាំឆ្នាំ និងបន្ទាប់ពីទទួលបានការងារជាមួយគម្រោង។ |
| បានកែប្រែ | 12/16/19 | 1. កំណត់និយមន័យ "បុគ្គលិកដែលបានជ្រើសតាំង" ឡើងវិញ<br>2. ធ្វើបច្ចុប្បន្នភាពនីតិវិធីដាក់ស្នើទម្រង់បែបបទ 700 ដើម្បី |

| ស្ថានភាព | កាលបរិច្ឆេទកែប្រែ | សេចក្តីសង្ខេបអំពីកំណែ |
|---|---|---|
| | | រាប់បញ្ចូលតែ Des (អ្នកសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ ឬអ្នកមានឥទ្ធិពល)<br>3. លក្ខខណ្ឌតម្រូវក្នុងការបញ្ចេញព័ត៌មាន HPSJ/MVHP ផ្អែកលើតម្រូវការជាជាងការជួលបុគ្គលិកថ្មី និងប្រចាំឆ្នាំ<br>4. បានបញ្ចូលលក្ខខណ្ឌតម្រូវដើម្បីចុះហត្ថលេខាការទទួលស្គាល់បន្ទាប់ពីទទួលបានការងារ និងប្រចាំឆ្នាំបន្ទាប់ពីបានពិនិត្យមើលគោលការណ៍នេះ។ |

| ស្ថានភាព | កាលបរិច្ឆេទកែប្រែ | សេចក្តីសង្ខេបអំពីកំណែ |
|---|---|---|
| បានកែប្រែ | 06/29/2020 | បានធ្វើបច្ចុប្បន្នភាពក្បាលទំព័រ និងរចនាបថពុម្ពអក្សរ។ |
| បានពិនិត្យមើល | 04/05/2021 | គ្មានការផ្លាស់ប្តូរសំខាន់ៗទេ។ |
| បានកែប្រែ | 08/05/21 | សមាជិកគណៈកម្មាការត្រូវបានបញ្ចូល ដើម្បីកែតម្រូវចន្លោះខ្វះខាតចំពោះបុគ្គលដែលបានកំណត់អត្តសញ្ញាណ។ (សូមមើលគោលបំណង, ចំណុច D ក្នុងគោលការណ៍, ចំណុច N ក្នុងនីតិវិធី) |